**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៥១...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការធ្វើចំណាត់ថ្នាក់ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ បរិវេណដីនៅខេត្តសៀមរាប សំរាប់ការអភិវឌ្ឍន៍ប្រព័ន្ធបង្ហូរទឹកកខ្វក់ និងសំរាប់សាងសង់ស្ថានីយ៍ចំរោះទឹកកខ្វក់

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ: នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ: ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ : នស/ រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញព្រះរាជក្រមលេខ : នស/រកម/០៨០១/១២ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ : ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រកាសលេខ ១៥១ សហវ.ប្រក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៤
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា ១ .-**

ត្រូវបានកំណត់បរិវេណដី សំរាប់ធ្វើការអភិវឌ្ឍន៍ប្រពន្ធ័បង្ហូរទឹកកខ្វក់ និងសំរាប់សាងសង់ស្ថានីយ៍ចំរោះទឹកកខ្វក់ ដែលមានទីតាំងស្ថិតនៅ ភូមិថ្មី ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។

**មាត្រា ២ .-**

ត្រូវបានធ្វើចំណាត់ថ្នាក់បរិវេណដី ដូចមានបញ្ជាក់ក្នុងប្លង់ឧបសម្ព័ន្ធ ដែលមានផ្ទៃក្រឡាសរុប ២៥ ហិកតា ជាប្រភេទដីមានលក្ខណៈសម្បត្តិជាទ្រព្យសាធារណៈរបស់រដ្ឋ ដែលមានទីតាំងស្ថិតនៅ ភូមិថ្មី ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ប្រកបដោយរបបគតិយុត្ត ដូចមានចែងក្នុងមាត្រា ១៥, មាត្រា ១៦, មាត្រា ១៧ នៃច្បាប់ភូមិបាល ចុះថ្ងៃទី ៣១ សីហា ឆ្នាំ ២០០១ ដើម្បីសម្រេចនូវគម្រោងនេះ និងមាននិយាមការ ដូចខាងក្រោម ÷

| | |
|---|---|
| E= 374408-N=1474758, | E = 373807 - N = 1474435, |
| E= 374493-N=1474068, | E =374401 - N=1473521, |
| E= 374367-N=1473523, | E =374348 - N=1473373, |
| E= 374274-N=1473376, | E = 374171- N=1473294, |
| E= 373251-N=1473604, | E =373431 - N=1474493, |
| E= 373642-N=1474460, | E =374402 - N=1474869. |

**មាត្រា ៣ .-**

រាល់ការទន្ទ្រានយកដី ការដោះដូរ ការទិញលក់ ឬការផ្ទេរកម្មសិទ្ធិ ការចេញបំណ្ណសិគាល់សិទ្ធិកាន់កាប់នៃអចលនៈវត្ថុទាំងឡាយ តាមគ្រប់រូបភាពទាំងអស់ ទោះស្របច្បាប់ក៏ដោយ ដែលស្ថិតក្នុងបរិវេណដីបង្គុកដូចបានពណ៌នាខាងលើនេះ និងការចេញលិខិតអនុញ្ញាតឱ្យសាងសង់សំណង់ថ្មី ត្រូវបានហាមឃាត់ លើកលែងតែការផ្ទេរកម្មសិទ្ធិជាផលប្រយោជន៍សាធារណៈ ។

រាល់ការបំពានលើបទប្បញ្ញត្តិ ដូចមានចែងខាងលើ អ្នកប្រព្រឹត្តល្មើសនឹងទទួលទណ្ឌកម្មដែលមានចែងនៅក្នុងមាត្រា ២៥៩ នៃច្បាប់ភូមិបាល ចុះថ្ងៃទី ៣១ សីហា ឆ្នាំ ២០០១ ។

**មាត្រា ៤ .-**

ម្ចាស់កម្មសិទ្ធិ ឬភោគីនៃឡូត៍ដី ក្នុងបរិវេណដែលនឹងត្រូវផ្ទេរកម្មសិទ្ធិ ឬភោគៈមកប្រគល់ឱ្យរដ្ឋ នឹងទទួលបាននូវការទូទាត់សំណង ក្រោមកិច្ចការអង្កេត នឹងការឯកភាពលើសំណើសំណង ស្នើឡើងដោយគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ដោយសារគំរោងការអភិវឌ្ឍន៍ប្រពន្ធ័បង្ហូរទឹកកខ្វក់ និងសំរាប់សាងសង់ស្ថានីយ៍ចំរោះទឹកកខ្វក់ខាងលើនេះ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ , ក្រសួងសាធារណការ និងដឹកជញ្ជូន , ក្រសួងទេសចរណ៍ និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធ ព្រមទាំងអភិបាលខេត្តសៀមរាប ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៦ .-**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ភ្នំពេញ, ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ